**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ : ៤៥ សសរ**

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មាធិការរៀបចំថ្នាក់ជាតិ ចូលរួមក្នុងសន្និសីទកំពូលស្តីពីការអភិវឌ្ឍន៍ដោយចិរភាព ឆ្នាំ ២០០២

******

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៤ / ២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៥៧ / អនក្រ.បក / ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងបរិស្ថាន
- ដោយអនុលោមតាមទិសដៅសន្និសីទអង្គការសហប្រជាជាតិស្តីពីបរិស្ថាន និងការអភិវឌ្ឍន៍ ដែលបានប្រព្រឹត្តទៅនៅទីក្រុង Rio de Janeiro ឆ្នាំ ១៩៩២
- យោងតាមសំណើរបស់ក្រសួងបរិស្ថាន និងការងាររបស់រាជរដ្ឋាភិបាល

**សំរេច**

**ប្រការ ១ :** បង្កើតគណៈកម្មាធិការរៀបចំថ្នាក់ជាតិមួយ ដើម្បីសំរបសំរួល រៀបចំត្រៀមចូលរួមក្នុងសន្និសីទកំពូល ស្តីពីការអភិវឌ្ឍន៍ដោយចិរភាព ឆ្នាំ ២០០២ នៅទីក្រុង Johannesburg ប្រទេសអាហ្វ្រិក ខាងត្បូង ។

www.pheakdeylaw.com

**ប្រការ ២** : សមាសភាពគណៈកម្មាធិការនេះរួមមាន :

| | |
|---|---|
| ១- ក្រសួងបរិស្ថាន | ជាប្រធាន |
| ២- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ជាសមាជិក |
| ៣- ក្រសួងផែនការ | ជាសមាជិក |
| ៤- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ជាសមាជិក |
| ៥- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ជាសមាជិក |
| ៦- ក្រសួងទេសចរណ៍ | ជាសមាជិក |
| ៧- ក្រសួងអភិវឌ្ឍន៍ជនបទ | ជាសមាជិក |
| ៨- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| ៩- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ជាសមាជិក |
| ១០- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ជាសមាជិក |
| ១១- គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ | ជាសមាជិក |

គណៈកម្មាធិការនេះ មានសិទ្ធិអញ្ជើញតំណាងអង្គការក្រៅរដ្ឋាភិបាល ចូលរួមប្រជុំផ្តល់យោបល់ តាមការចាំបាច់ ។

**ប្រការ ៣** : គណៈកម្មាធិការនេះមានភារៈកិច្ចដូចតទៅ :

ក- រៀបចំឯកសារស្តីពីការវាយតំលៃថ្នាក់ជាតិ អំពីកិច្ចខិតខំប្រឹងប្រែង និងទស្សនវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា ចំពោះការអភិវឌ្ឍន៍ដោយចិរភាព ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសំរេច

ខ- រៀបចំសន្និសីទ ត្រៀមសំរាប់តំបន់អាស៊ីប៉ាស៊ីហ្វិក ដែលនឹងប្រព្រឹត្តទៅនៅទីក្រុងភ្នំពេញ ពីថ្ងៃទី ២៧ ដល់ ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០១ មុនសន្និសីទកំពូលស្តីពីការអភិវឌ្ឍន៍ដោយចិរភាព ។

**ប្រការ ៤** : គណៈកម្មាធិការ ត្រូវសហការទំនាក់ទំនងអោយបានជិតស្និតជាមួយក្រុមការងារតំបន់នៃសន្និសីទកំពូលស្តីពីការអភិវឌ្ឍន៍ដោយចិរភាព ដែលក្នុងនោះមាន ESCAP UNEP UNDP និងធនាគារអភិវឌ្ឍន៍អាស៊ី ADB ភ្នាក់ងាររបស់អង្គការសហប្រជាជាតិ ដៃគូរទ្វេភាគីតំណាងសង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាល សាកលវិទ្យាល័យ និងភាគីពាក់ព័ន្ធដទៃទៀត ។

**ប្រការ ៥** : គណៈកម្មាធិការនេះមានលេខាធិការដ្ឋានមួយជាជំនួយការ ដែលមានទីតាំងនៅក្រសួងបរិស្ថាន ។

**ប្រការ ៦** : លេខាធិការដ្ឋានរបស់គណៈកម្មាធិការនេះ ត្រូវបានដឹកនាំដោយលេខាធិការមួយរូប ហើយមានអ្នកជំនាញការជាតិ និងអន្តរជាតិបន្ថែមមួយចំនួនទៀត តាមតំរូវការចាំបាច់ ដើម្បីអនុវត្តការងារតាមភារកិច្ចដែលគណៈកម្មាធិការប្រគល់អោយ ។ គណៈកម្មាធិការនេះមានសិទ្ធប្រើប្រាស់ត្រារបស់ក្រសួងបរិស្ថាន ។

www.pheakdeylaw.com

**ប្រការ ៧ :** ខ្លឹមសារនៃការវាយតំលៃថ្នាក់ជាតិ ត្រូវផ្ដោតជាអាទិ៍ទៅលើ :

១- ការវាយតំលៃពីសភាពការណ៍នៃការអនុវត្តន៏យុទ្ធសាស្ត្រ គន្លឹះគំនិតផ្ដួចផ្ដើម ការអភិវឌ្ឍន៍ដោយចិរភាពនៅកម្ពុជា ក៏ដូចជាការអនុវត្តន៍ និងការប្រតិបត្តិរបស់រាជរដ្ឋាភិបាលកម្ពុជា ចំពោះកិច្ចការអន្តរជាតិដែលទាក់ទងនឹងការអភិវឌ្ឍន៍ដោយចិរភាព

២- កំណត់ពីបញ្ហាគន្លឹះ និងបទពិសោធដែលទទួលបាន

៣- ផ្អែកលើមូលដ្ឋាននៃការវាយតំលៃនេះ ត្រូវលើកឡើងពីចក្ខុវិស័យទៅអនាគតរបស់រាជរដ្ឋាភិបាលកម្ពុជា ចំពោះការអភិវឌ្ឍន៍ដោយចិរភាព ។

**ប្រការ ៨ :** ក្នុងការរៀបចំឯកសារស្ដីពីការវាយតំលៃថ្នាក់ជាតិ គណៈកម្មាធិការត្រូវយកចិត្តទុកដាក់ ជាអាទិ៍លើកិច្ចដំណើរការដូចខាងក្រោមនេះ :

- រៀបចំសិក្ខាសាលាសំរាប់អ្នកដែលពាក់ព័ន្ធសំខាន់ៗ ដើម្បីជួយកំណត់វិសាលភាព និងវិធីសាស្ត្រនៃការវាយតំលៃ និងរបៀបដែលត្រូវអនុវត្ត
- ចាត់តាំងអ្នកសំរបសំរួល ដើម្បីដឹកនាំកិច្ចដំណើរការវាយតំលៃដោយមានជំនួយគាំទ្រពីជំនាញការអន្តរជាតិ ហើយអាចបន្ថែមជំនាញការជាតិ និងអន្តរជាតិមួយចំនួនទៀត ទៅតាមតំរូវការជាក់ស្ដែង
- ពិគ្រោះយោបល់ដើម្បីកំណត់អំពីបញ្ហាគន្លឹះ បទពិសោធន៍ដែលបានទទួល និងកំណត់ចក្ខុវិស័យទៅអនាគតរបស់រាជរដ្ឋាភិបាលកម្ពុជា ពីបញ្ហាចិរភាព
- រៀបចំសេចក្ដីព្រាង និងបញ្ចប់របាយការណ៍ ។
- សមាជិកគណៈកម្មាធិការនេះ ត្រូវចូលប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មាធិការ

**ប្រការ ៩ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធនឹងសេចក្ដីសំរេចនេះ ត្រូវសហការអនុវត្តអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០១*

*ចម្លងជូន :*

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
*-ដូចប្រការ ៩*
*-កាលប្បវត្តិ-ឯកសារ*

ហ៊ុន សែន